រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៥៩៧២ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការប្តូរសញ្ញានិងត្រារបស់បណ្ឌិត្យសភានគរបាលកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៤អនក្រ.បក ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពីការបង្កើតសញ្ញារបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

## សម្រេច

**ប្រការ១.-**

ត្រូវបានប្តូរសញ្ញានិងត្រា ព្រមទាំងដាក់ឱ្យប្រើសញ្ញាថ្មីនិងត្រាថ្មីរបស់បណ្ឌិត្យសភានគរបាលកម្ពុជាជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

សញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជា មានទម្រង់និងលក្ខណៈដូចខាងក្រោម៖

- មានរាងជារង្វង់មូល រឹមកងចក្រព័ទ្ធជុំវិញពណ៌ផ្ទៃមេឃចំនួន២៥ លើផ្ទៃពណ៌ខៀវ
- ផ្នែកខាងក្នុងនៃរង្វង់កងចក្ររួមមាន នៅផ្នែកខាងលើមានអក្សរពណ៌ស ក្នុងផ្ទៃពណ៌ក្រហមរាងកោងស្របតាមរង្វង់មូលសរសេរថា «**ក្រសួងមហាផ្ទៃ**» ដែលអមដោយផ្កាចន្ទន៍ទាំងសងខាង។ ចំណែកផ្នែកខាងក្រោម

មានអក្សរពណ៌ស ក្នុងផ្ទៃបូពណ៌ក្រហមរាងកោងស្របតាមរង្វង់មូលសរសេរថា «**បណ្ឌិត្យសភានគរបាលកម្ពុជា**»។ នៅចន្លោះពាក្យ «**ក្រសួងមហាផ្ទៃ**» និងពាក្យ «**បណ្ឌិត្យសភានគរបាលកម្ពុជា**» មានធ្នូតទទឹងពណ៌បៃតងចំនួន៣ធ្នូតទាំងសងខាងនិងធ្នូតបណ្ដោយពណ៌មាស៣ធ្នូតទាំងសងខាង។

- ផ្នែកខាងក្នុងចំកណ្ដាល មានរូបព្រះគណេសពណ៌មាស ឈរត្រើមចង្កេះឡើងលើ នៅចំពីលើព្រះកេសព្រះគណេស មានអក្សរជាភាសាអង់គ្លេសពណ៌មាសរាងកោងស្របតាមរង្វង់មូលសរសេរថា «MINISTRY OF INTERIOR» រីឯនៅខាងក្រោមរូបព្រះគណេស មានផ្កាចន្ទន៍ចំនួន៧ពណ៌មាស ហើយនៅខាងក្រោមផ្កាចន្ទន៍ មានអក្សរជាភាសាអង់គ្លេសពណ៌មាសរាងកោងស្របតាមរង្វង់មូលសរសេរថា «POLICE ACADEMY OF CAMBODIA»។

**ប្រការ៣.-**

សញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជាមានអត្ថន័យ ដូចខាងក្រោម៖

- **រង្វង់មូល** តំណាងឱ្យភពផែនដីទាំងមូល
- **រឹមកងចក្រព័ទ្ធជុំវិញជារង្វង់មូលចំនួន២៥** តំណាងឱ្យរាជធានីនិងខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា
- **រូបព្រះគណេស** ជាអាទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គនិងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះ ព្រះគណេស តំណាងឱ្យភាពជាអ្នកប្រាជ្ញ ជាបណ្ឌិត ជាអ្នកចេះដឹងអ្នកជួយសង្គ្រោះដល់សត្វលោកទាំងឡាយបានគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ព្រមទាំងបង្កើតឱ្យមានភាពសម្បូរសប្បាយរុងរឿង វឌ្ឍនភាព និងវិបុលភាព
- **សញ្ញាផ្កាចន្ទន៍ទាំង៧ក្រោមរូបព្រះគណេស** តំណាងឱ្យសាលាបណ្ដុះបណ្ដាលទាំង៧នៅតាមបណ្ដាខេត្តនានា រួមមានសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងសាលានគរបាលជាតិភូមិភាគទាំង៦ ដែលចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា
- **ធ្នូតទទឹងពណ៌បៃតងចំនួន៣ធ្នូតទាំងសងខាង** តំណាងឱ្យជីវិតនិងធម្មជាតិ
- **ធ្នូតបណ្ដោយពណ៌មាសចំនួន៣ធ្នូតទាំងសងខាង** តំណាងឱ្យគោលការណ៍ទាំង៣គឺ គោលការណ៍សមធម៌ គោលការណ៍គុណភាព និងគោលការណ៍មិនលម្អៀង
- **ពណ៌មាស** តំណាងឱ្យភាពឧត្តុង្គឧត្តម សេចក្ដីថ្លៃថ្នូរ និងគុណភាព
- **ពណ៌ខៀវនិងពណ៌ផ្ទៃមេឃ** តំណាងឱ្យសុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព
- **ពណ៌ស** តំណាងឱ្យភាពបរិសុទ្ធ សុក្រឹតភាព សុចរិតភាព និងភាពមិនលម្អៀងដោយអគតិទាំង៤ក្នុងការបណ្ដុះបណ្ដាល
- **ពណ៌ក្រហម** តំណាងឱ្យការប្ដេជ្ញាចិត្ត ភាពអង់អាចក្លាហាន និងកម្លាំងអនុភាពរបស់បណ្ឌិត្យសភានគរបាលកម្ពុជាក្នុងការកសាងធនធានមនុស្ស ព្រមទាំងជំរុញឱ្យអង្គភាពចំណុះនិងអ្នកសិក្សាបំពេញបានតាមស្តង់ដាគុណភាពដែលបានកំណត់។

**ប្រការ៤.-**

សញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជាប្រើជាផ្លូវការ ដូចខាងក្រោម៖

- ធ្វើត្រាមូលរបស់បណ្ឌិត្យសភានគរបាលកម្ពុជា
- ដាក់នៅកន្លែងធ្វើការងារ

- ដាក់នៅលើដៃអាវខាងឆ្វេងនៃឯកសណ្ឋានមន្ត្រីនគរបាលជាតិនិងអ្នកសិក្សានៃបណ្ឌិត្យសភានគរបាលកម្ពុជា
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការរបស់បណ្ឌិត្យសភានគរបាលកម្ពុជា
- ប្រើជាផ្លូវការក្នុងពិធី និងក្នុងករណីផ្សេងៗទៀត។

**ប្រការ៥ .-**

ត្រារបស់បណ្ឌិត្យសភានគរបាលកម្ពុជា មានទំហំនិងលក្ខណៈដូចខាងក្រោម៖

- មានទំហំអង្កត់ផ្ចិត៤១មម.
- មានរាងជារង្វង់មូលដែលក្នុងនោះរង្វង់ខាងក្រៅមានឆ្នូត២ជាន់ និងរង្វង់ខាងក្នុងមានឆ្នូត១ជាន់
- នៅចន្លោះនៃរង្វង់ទាំង២ជាន់ផ្នែកខាងលើមានអក្សរសរសេរថា «**ក្រសួងមហាផ្ទៃ**» ដែលមានរាងកោងស្របតាមរង្វង់មូល និងនៅផ្នែកខាងក្រោមមានអក្សរសរសេរថា «**បណ្ឌិត្យសភានគរបាលកម្ពុជា**» ដែលមានរាងកោងស្របតាមរង្វង់មូល
- នៅចន្លោះនៃរង្វង់ទាំង២និងចន្លោះពាក្យថា «**ក្រសួងមហាផ្ទៃ**» និងពាក្យថា «**បណ្ឌិត្យសភានគរបាលកម្ពុជា**» មានសញ្ញាផ្កាចន្ទន៍ចំនួន២នៅសងខាង
- ផ្នែកចំកណ្តាលនៃរង្វង់តូចផ្នែកខាងក្នុង មានរូបព្រះគណេស ឈរត្រឹមចង្កេះឡើងលើ។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានអង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១០កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ...៥៩៧១ ប្រក......

ចុះថ្ងៃ ...សុក្រ ១០ កើត......ខែ...មិគសិរ........ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវនឹងថ្ងៃទី...២២.....ខែ....ធ្នូ........ឆ្នាំ២០២៣

ស្ដីពីការប្ដូរសញ្ញា និងត្រារបស់បណ្ឌិត្យសភានគរបាលកម្ពុជា

១. សញ្ញារបស់បណ្ឌិត្យសភានគរបាលកម្ពុជា

២. ត្រារបស់បណ្ឌិត្យសភានគរបាលកម្ពុជា